ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅណែនាំ
# ស្តីពី
# ពន្ធលើដីធ្លី
# មិនបានប្រើប្រាស់

ចែករំលែកដោយៈ មេធាវីតម្រាច្បាប់
www.legalcodelawfirm.com
www.facebook.com/legalcodelawoffice
**App Store & Play Store: LEGAL CODE LIBRARY (បណ្ណាល័យតម្រាច្បាប់)**

## អគ្គនាយកដ្ឋានពន្ធដារ

# សៀវភៅណែនាំ
# ស្ដីពី
# ពន្ធលើដីធ្លីមិនបានប្រើប្រាស់



២០២១

# សេចក្តីផ្តើម

សៀវភៅណែនាំស្តីពី “**ពន្ធលើដីធ្លីមិនបានប្រើប្រាស់**” ត្រូវបានរៀបរៀងឡើងដោយនាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យនៃអគ្គនាយកដ្ឋានពន្ធដារ អនុលោមតាមមាត្រា៩៦ នៃច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧ និងស្របតាមការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ របស់រាជរដ្ឋាភិបាលកម្ពុជា និងផែនការយុទ្ធសាស្ត្រ ២០១៩-២០២៣ របស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងគោលបំណងផ្សព្វផ្សាយចំណេះដឹងជូនសាធារណជន និងអ្នកជាប់ពន្ធឱ្យបានយល់ដឹងកាន់តែទូលំទូលាយអំពីទិដ្ឋភាពច្បាប់ បទប្បញ្ញត្តិនានា និងនីតិវិធីនៃការបង់ពន្ធ ព្រមទាំងជាជំនួយស្មារតីបន្ថែមទៀត ក្នុងការបញ្ច្រាបវប្បធម៌បង់ពន្ធ និងបំពេញកាតព្វកិច្ចបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ឱ្យបានត្រឹមត្រូវ ច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ។

មាតិកានៃសៀវភៅនេះ ត្រូវបានជ្រើសរើស និងសម្រិតសម្រាំងជាពិសេសដើម្បីបកស្រាយនូវចម្ងល់នានាពាក់ព័ន្ធនឹងពន្ធនេះ ដោយត្រូវបានបែងចែកជា ៥ ផ្នែកសំខាន់ៗដូចជា÷ ផ្នែកទី ១ បង្ហាញអំពីទិដ្ឋភាពច្បាប់ និងបទប្បញ្ញត្តិនានាដោយដកស្រង់នូវពាក្យគន្លឹះ និងខ្លឹមសារសំខាន់ៗមកធ្វើការពន្យល់បន្ថែមឱ្យកាន់តែងាយយល់។ ផ្នែកទី ២ ផ្តោតទៅលើអត្រាពន្ធ មូលដ្ឋានកំណត់ពន្ធ និងការគណនាប្រាក់ពន្ធ។ ផ្នែកទី ៣ បង្ហាញអំពីកាតព្វកិច្ចអ្នកជាប់ពន្ធ និងនីតិវិធីសារពើពន្ធនៃការដាក់ពាក្យស្នើសុំបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់។ ដោយឡែក ទោសទណ្ឌ និងសិទ្ធិក្នុងការតវ៉ារបស់អ្នកជាប់ពន្ធត្រូវបានរំលេចនៅផ្នែកទី ៤ ហើយផ្នែកបញ្ចប់ បានបង្ហាញអំពីសេវាអ្នកជាប់ពន្ធដែលអគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងខិតខំប្រឹងប្រែងដោះស្រាយបញ្ហានានាជូនអ្នកជាប់ពន្ធ និងព័ត៌មានបន្ថែមសម្រាប់អ្នកជាប់ពន្ធធ្វើការទំនាក់ទំនងក្នុងករណីមានចម្ងល់បន្ថែម។

# មាតិកា

**ផ្នែកទី១ លក្ខណៈទូទៅនៃពន្ធលើដីធ្លីមិនបានប្រើប្រាស់ ............ ១**

១.១. សាវតារ និងកម្មវត្ថុនៃពន្ធ ............ ១

១.២. និយមន័យនៃពាក្យសំខាន់ៗ ............ ១

១.៣. លក្ខណៈដែលចាត់ទុកជាដីធ្លីបានប្រើប្រាស់ ............ ១

**ផ្នែកទី២ អត្រាពន្ធ មូលដ្ឋានកំណត់ពន្ធ និងការគណនាប្រាក់ពន្ធ ............ ៥**

២.១. អត្រាពន្ធ ............ ៥

២.២. មូលដ្ឋានកំណត់ពន្ធ ............ ៥

២.៣. ការគណនាប្រាក់ពន្ធ ............ ៦

**ផ្នែកទី៣ កាតព្វកិច្ច និងនីតិវិធីនៃការប្រកាសបង់ពន្ធ ............ ៧**

៣.១. កាតព្វកិច្ចនៃការដាក់លិខិតប្រកាស និងការបង់ប្រាក់ពន្ធ ............ ៧

៣.២. នីតិវិធីនៃដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធ ............ ៧

៣.៣. ទំនាក់ទំនងរវាងពន្ធលើអចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់ ............ ៨

៣.៤. ឯកសារតម្រូវសម្រាប់ការបង់ពន្ធ ............ ៨

**ផ្នែកទី៤ ទោសទណ្ឌ និងសិទ្ធិក្នុងការតវ៉ា ............ ១១**

៤.១. ការយឺតយ៉ាវក្នុងការបំពេញកាតព្វកិច្ច ............ ១១

៤.២. សិទ្ធិក្នុងការតវ៉ា ............ ១១

៤.៣. ពាក្យបណ្តឹងតវ៉ា ............ ១១

**ផ្នែកទី៥ សេវាអ្នកជាប់ពន្ធ និងព័ត៌មានបន្ថែម ............ ១៣**

៥.១. ចម្ងល់ផ្សេងៗ និងការពិគ្រោះយោបល់ ............ ១៣

**ឧបសម្ព័ន្ធ៖ ច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធលើដីធ្លីមិនបានប្រើប្រាស់ ............ ១៦**

ផ្នែកទី១

# លក្ខណៈទូទៅនៃពន្ធលើដីធ្លីមិនបានប្រើប្រាស់

## ១.១. សាវតារ និងកម្មវត្ថុនៃពន្ធ

**ពន្ធលើដីធ្លីមិនបានប្រើប្រាស់** ត្រូវបានបង្កើតឡើង ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១ ន.ស ៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ១៩៩៦។ គោលបំណងនៃពន្ធនេះគឺដើម្បី (១)ទប់ស្កាត់រាល់រូបភាពទិញដីទុកមិនប្រើប្រាស់រង់ចាំពេលឡើងថ្លៃលក់យកកម្រៃលើស (២)ជំរុញការប្រើប្រាស់ដីធ្លីឱ្យបានសមស្របនិងមានការអភិវឌ្ឍ (៣)បង្កើនសកម្មភាពសេដ្ឋកិច្ចនិងកម្លាំងការងារ និង (៤)រួមចំណែកដើម្បីជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ គឺប្រមូលចំពោះអចលនទ្រព្យទាំងឡាយណាដែលត្រូវបានចាត់ទុកជា **“ដីធ្លីមិនបានប្រើប្រាស់”** ដូចមានចែងក្នុងនិយមន័យខាងក្រោម។

## ១.២. និយមន័យនៃពាក្យសំខាន់ៗ

**“កម្មសិទ្ធិករ”** សំដៅដល់បុគ្គលណាដែលផ្អែកសុរិយោដី ឬអាជ្ញាធរដែនដី ចាប់ពីថ្នាក់ឃុំ-សង្កាត់ឡើងទៅ បានចេញឯកសារផ្លូវការទទួលស្គាល់សិទ្ធិរបស់បុគ្គលនោះ ក្នុងការប្រើប្រាស់ដីក្នុងតំបន់ណាមួយ ជាលក្ខណៈជាប់លាប់ក្តី ឬបណ្តោះអាសន្នក្តី។ កម្មសិទ្ធិករម្នាក់ គឺជាក្រុមគ្រួសារមួយ “ឪពុក ម្តាយ សាមីខ្លួន ប្រពន្ធ កូនក្នុងបន្ទុក” ឬមេគ្រួសារ និងសមាជិកក្នុងបន្ទុកមានឈ្មោះក្នុងប័ណ្ណគ្រួសារ ដែលចេញដោយស្ថាប័នមានសមត្ថកិច្ច។

**“គណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់”** មានសមាសភាពកំណត់ដោយអនុក្រឹត្យលេខ ៥៨ អ.ន.ក្រ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥។ គណៈកម្មការនេះមានភារកិច្ច÷

- បង្កើតបញ្ជីរាយឈ្មោះទីក្រុង និងតំបន់ដែលមានដីត្រូវជាប់ពន្ធ
- កំណត់ប្រចាំឆ្នាំនូវតម្លៃដីក្នុង ១ម៉ែត្រក្រឡា
- ផ្តល់មតិចំពោះរឿងវិវាទ។

**“ដីធ្លីមិនបានប្រើប្រាស់”** សំដៅដល់ដីធ្លីទាំងឡាយដែលពុំមានលក្ខណៈណាមួយនៃលក្ខណៈទាំង៥ ដូចមានចែងក្នុងប្រការ១ នៃប្រកាសលេខ ២២៤ ប្រក.សហវ.ពដ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៦ (សូមមើលចំណុច ១.៣)។

## ១.៣. លក្ខណៈដែលចាត់ទុកជាដីធ្លីបានប្រើប្រាស់

### ១. ដីមានសំណង់ស្ថិតក្នុងតំបន់លំនៅដ្ឋាន



ដីមានសំណង់ស្ថិតក្នុងតំបន់លំនៅដ្ឋាន ដែលកម្មសិទ្ធិករប្រើប្រាស់ ជាកន្លែងស្នាក់នៅជាសំខាន់របស់ខ្លួន និងបានស្នាក់នៅកន្លែងនេះ ចំនួន ១៨៣ថ្ងៃ ឬច្រើនជាង គិតចាប់ពីថ្ងៃទី០១ ខែតុលា នៃឆ្នាំកន្លង ទៅរហូតដល់ថ្ងៃទី៣០ ខែកញ្ញា នៃឆ្នាំប្រមូលពន្ធ។ កន្លែងស្នាក់នៅជាគោលសំខាន់របស់កម្មសិទ្ធិករ គឺជាកន្លែងដែលកម្មសិទ្ធិករបានដេកនៅ ហូបចុកយ៉ាងជាក់លាក់ជារៀងរាល់ថ្ងៃ ក្រោយពីពេលត្រឡប់មកពីបំពេញការងារប្រចាំថ្ងៃ។ សម្រាប់ការកំណត់ពន្ធនេះ កម្មសិទ្ធិករម្នាក់ពុំអាចមានទីកន្លែងស្នាក់នៅជាគោលសំខាន់លើសពីមួយកន្លែងបានទេ។

## ២. ដីជួលដែលមានសំណង់មានការកាន់កាប់

ដីស្ថិតនៅក្នុងតំបន់លំនៅដ្ឋាន ឬស្ថិតនៅក្នុងតំបន់ដែលមានសកម្មភាពសេដ្ឋកិច្ចដូចជា តំបន់ឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម ទេសចរណ៍... ហើយដីនោះមានសំណង់ផ្សេងៗ ដូចជាលំនៅដ្ឋាន អគារ ឃ្លាំង...ដែលបានជួលទាំងដីព្រមទាំងសំណង់ទៅឱ្យអតិថិជន ដើម្បីយកឈ្នួលប្រចាំខែ ប្រចាំឆ្នាំ ឬក្រោមកិច្ចសន្យារយៈពេលវែង។ ដីប្រភេទនេះត្រូវចាត់ទុកជាដីធ្លីប្រើប្រាស់ ដែលមិនត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ លុះណាតែដីទាំងនោះផ្តល់លាភការប្រចាំខែលើសពី ៨០% នៃចំនួនមួយភាគដប់ពីរនៃតម្លៃដីនៅក្នុងឆ្នាំប្រមូលពន្ធគុណនឹងមេគុណ ដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយក្នុងនោះតម្លៃដីត្រូវបានកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់។

មេគុណសម្រាប់វាយតម្លៃលាភការប្រចាំខែ ត្រូវបានកំណត់ស្មើនឹង ០,០៨ ក្នុងប្រការ១ នៃប្រកាសលេខ ៧៤៤ ប្រក.សហវ.ពដ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៩៦។



**ឧទាហរណ៍÷** ដីឡូតិ៍ដែលមានសំណង់មួយកន្លែងស្ថិតនៅជាយរាជធានីភ្នំពេញ មានទំហំ ២០ម x ៦០ម កម្មសិទ្ធិករបានដាក់ជួលក្នុងតម្លៃ ១ ៦០០ ០០០៛/មួយខែ។ គេដឹងថាតម្លៃមូលដ្ឋានគិតពន្ធលើដីធ្លីមិនបានប្រើប្រាស់ កំណត់ដោយគណៈកម្មការវាយតម្លៃដីគឺ ៤០ ០០០៛/ម²។ តើដីជួលមួយកន្លែងនេះជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ដែរឬទេ?

**ចម្លើយ÷** ដើម្បីកំណត់បានថាដីនេះត្រូវជាប់ពន្ធ ឬមិនជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ យើងត្រូវគណនារកលាភការប្រចាំខែដែលកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនប្រើប្រាស់ដូចខាងក្រោម÷

| បរិយាយ | គណនា | លទ្ធផល |
|---|---|---|
| ផ្ទៃដីសរុប | ២០ម x ៦០ម | ១ ២០០ម² |
| តម្លៃដីសរុប | ១ ២០០ម² x ៤០ ០០០៛/ម² | ៤៨ ០០០ ០០០៛ |
| លាភការប្រចាំខែកំណត់ដោយគណៈកម្មការ | (៤៨ ០០០ ០០០៛ ÷ ១២) x ០,០៨ | ៣២០ ០០០៛ |
| លាភការប្រចាំខែកំណត់ដោយគណៈកម្មការ (៨០%) | ៣២០ ០០០៛ x ៨០% | ២៥៦ ០០០៛ |
| លាភការពីការជួលដីក្នុង១ខែ | | ១ ៦០០ ០០០៛ |

ដោយលាភការប្រចាំខែទទួលបានពីការជួលដីនេះ ចំនួន ១ ៦០០ ០០០ រៀល លើសពី ៨០% នៃលាភការប្រចាំខែដែលកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ ចំនួន ២៥៦ ០០០ រៀល **ដូច្នេះ ដីនេះមិនត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់នោះទេ។**

### ៣. ដីដែលមានសកម្មភាពសេដ្ឋកិច្ច

ដីប្រភេទនេះ សំដៅដល់ដីដែលកម្មសិទ្ធិករប្រើប្រាស់សម្រាប់សកម្មភាពសេដ្ឋកិច្ចដូចជា ដាំដុះ ឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍ ស្របតាមការកំណត់តំបន់របស់រដ្ឋ។ ដីប្រភេទនេះត្រូវចាត់ទុកជាដីធ្លីប្រើប្រាស់មិនត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ លុះត្រាតែប្រាក់ចំណូលប្រចាំខែបានមកពីសកម្មភាពសេដ្ឋកិច្ចទាំងនោះលើសពីចំនួន ៨០% នៃចំនួនមួយភាគដប់ពីរនៃតម្លៃដីនៅក្នុងឆ្នាំប្រមូលពន្ធគុណនឹងមេគុណ ដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយក្នុងនោះតម្លៃដីត្រូវកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់។



សារាចរណែនាំស្តីពីការអនុវត្តពន្ធលើដីធ្លីមិនបានប្រើប្រាស់លេខ ០១៧ សរន.សហវ.ពដ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៩ ក្នុងចំណុច ១-គ បានចែងថា “...ត្រូវកត់សម្គាល់ និងយកចិត្តទុកដាក់លើការខុសគ្នារវាងដីដាំដុះរបស់ប្រជាពលរដ្ឋធ្វើស្រែចំការពិតប្រាកដ ដែលមិនត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងដីរបស់អាជីវករករស៊ីទិញលក់ដីដោយមិនធ្វើអាជីវកម្មលើដីនោះដោយខ្លួនឯង តែប្រគល់ឬប្រវាស់ឱ្យប្រជាជនធ្វើអាជីវកម្ម និងករណីដីមួយទៀត ក្រោយពីការជូនដំណឹងស្តីពីការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ អាជីវករទិញលក់ដីខ្លះបានយកដំណាំដូចជាចេក អំពៅ និងដំណាំហូបផ្លែផ្សេងៗទៀត មកដាំលើដីនោះបំភ័ន្តភ្នែក ប្រែក្លាយដីមិនបានប្រើប្រាស់ឱ្យមើលឃើញថាជាដីប្រើប្រាស់ក្នុងគោលបំណងគេចវេះមិនព្រមបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់។ ទាក់ទិននឹងដីខាងលើ ដើម្បីកំណត់ឱ្យបានច្បាស់ថាតើដីនោះជាដីប្រើប្រាស់ ឬជាដីមិនបានប្រើប្រាស់ ចាំបាច់ត្រូវគិតគូររកឱ្យឃើញនូវប្រាក់ចំណូលប្រចាំខែ ដែលបានមកពីសកម្មភាពសេដ្ឋកិច្ចដូចបានរៀបរាប់ខាងលើ”។

### ៤. ដីជាកម្មសិទ្ធិរបស់រដ្ឋជួលឱ្យនីតិបុគ្គល ឬរូបវន្តបុគ្គលណាមួយ

ដីប្រភេទនេះជាដីសាធារណៈ ដែលជាកម្មសិទ្ធិរបស់រដ្ឋ ទោះបីមានក្នុងបញ្ជីសារពើភណ្ឌ ឬក្រៅបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋក្តី ហើយដីនោះមានលក្ខណៈណាមួយនៃចំណុចទាំង៣ខាងលើ។

## ៥. ដីស្ថិតក្រោមកិច្ចព្រមព្រៀងវិនិយោគ

ដីប្រភេទនេះ រួមមានដីស្ថិតនៅក្រោមកិច្ចព្រមព្រៀងវិនិយោគនិងដីសម្បទាន ដែលបានការអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ឱ្យធ្វើវិនិយោគលើវិស័យអ្វីមួយ ឬដីសម្បទានរយៈពេលខ្លី មធ្យម ឬវែង ដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យអនុវត្តនូវគម្រោងអ្វីមួយ។ ប្រសិនបើដីវិនិយោគ ឬសម្បទាននោះពុំបាន ឬពុំទាន់ដំណើរការដោយមូលហេតុប្រធានសក្តិ ឬដោយមូលហេតុអសន្តិសុខផ្សេងៗនោះ ពុំត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ទេ ប៉ុន្តែលុះណាតែការអាក់ខាន ឬពន្យារពេលនោះ មានការបញ្ជាក់ទទួលយល់ព្រមពីស្ថាប័នជំនាញមានសមត្ថកិច្ច និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ផ្នែកទី២

# អត្រាពន្ធ មូលដ្ឋានកំណត់ពន្ធ និងការគណនាប្រាក់ពន្ធ

## ២.១. អត្រាពន្ធ

ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ត្រូវកំណត់តាមអត្រា **២%** លើមូលដ្ឋានកំណត់ពន្ធ។

## ២.២. មូលដ្ឋានកំណត់ពន្ធ

មូលដ្ឋានកំណត់ពន្ធ គឺជាថ្លៃដីគិតតាមថ្លៃទីផ្សារ តាមទីក្រុង និងតាមតំបន់នីមួយៗ ដែលវាយតម្លៃទៅតាមតម្លៃគិតក្នុងមួយម៉ែត្រក្រឡា ដែលកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់។

ការកំណត់បែងចែកតំបន់ និងតម្លៃដីក្នុងមួយម៉ែត្រក្រឡាសម្រាប់គិតពន្ធលើដីធ្លីមិនបានប្រើប្រាស់ មានចែងក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្ដីសម្រេចលេខ ០០៧ សសរ.សហវ.ពដ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ របស់គណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់។ ឧបសម្ព័ន្ធនេះត្រូវបានផ្សព្វផ្សាយជាសាធារណៈដែលសាធារណជន និងអ្នកជាប់ពន្ធអាចធ្វើការស្វែងរក និងទាញយកពីគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារតាមរយៈតំណភ្ជាប់ https://www.tax.gov.kh ដោយចូលទៅកាន់ ❶ **“ច្បាប់និងបទប្បញ្ញត្តិ”** រួចចុចត្រង់ចំណុច ❷ **“ច្បាប់”** បន្ទាប់មកសូមស្វែងរក **“លិខិតបទដ្ឋានស្ដីពីពន្ធលើដីធ្លីមិនបានប្រើប្រាស់”** រួចចុចលើប៊ូតុងទាញយក ❸ ដូចខាងក្រោម។



## ២.៣. ការគណនាប្រាក់ពន្ធ

### ១. ការគណនាប្រាក់ពន្ធត្រូវបង់សម្រាប់ការិយបរិច្ឆេទមុនឆ្នាំ២០០៧

ប្រាក់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវបង់ ស្មើនឹងផ្ទៃដីសរុប ដក ១ ២០០ម៉ែត្រក្រឡា គុណនឹងមូលដ្ឋានកំណត់ពន្ធ គុណនឹងអត្រាពន្ធ។

| ប្រាក់ពន្ធត្រូវបង់ = (ផ្ទៃដីសរុប - ១ ២០០ម$^{២}$) x មូលដ្ឋានកំណត់ពន្ធ x អត្រាពន្ធ |
|---|

### ២. ការគណនាប្រាក់ពន្ធត្រូវបង់សម្រាប់ការិយបរិច្ឆេទចាប់ពីឆ្នាំ២០០៧

ប្រាក់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវបង់ ស្មើនឹងផ្ទៃដីសរុប គុណនឹងមូលដ្ឋានកំណត់ពន្ធ គុណនឹងអត្រាពន្ធ។

| ប្រាក់ពន្ធត្រូវបង់ = ផ្ទៃដីសរុប x មូលដ្ឋានកំណត់ពន្ធ x អត្រាពន្ធ |
|---|

**សម្គាល់÷**

- ក្នុងការគិតពន្ធ ត្រូវបានអនុញ្ញាតឱ្យកាត់ចេញពីមូលដ្ឋានកំណត់ពន្ធចំនួន ១ ២០០ ម៉ែត្រក្រឡាក្នុងដីមួយកន្លែង យោងមាត្រា៣០ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- ការអនុញ្ញាតខាងលើ ត្រូវបានលុបដោយមាត្រា៣ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៧ និងប្រការ១ នៃប្រកាសលេខ ៤៥២ សហវ.ប្រក.ពដ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៧។

**ឧទាហរណ៍÷** លោក “ក” មានដីធ្លីមិនប្រើប្រាស់មួយកន្លែងទំហំ ៩ ០០០ម$^{២}$។ តម្លៃមូលដ្ឋានគិតពន្ធដែលកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់គឺ ១៥ ០០០៛/ម$^{២}$។ ចូរគណនាប្រាក់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ក្នុងឆ្នាំ២០២០?

**ចម្លើយ÷** ប្រាក់ពន្ធត្រូវបង់ = ៩ ០០០ម$^{២}$ x ១៥ ០០០៛ x ២% = <u>២ ៧០០ ០០០៛</u>

**សម្គាល់÷**

យោងលិខិតលេខ ៣៦៧ សជណ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី និងលិខិតលេខ ២៨៩១៧ អពដ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានពន្ធដារ អចលនទ្រព្យពុំបានចុះបញ្ជី (គ្មានប័ណ្ណកម្មសិទ្ធិ) ដែលបានផ្ទេរសិទ្ធិកាន់កាប់នៅថ្នាក់ឃុំ-សង្កាត់ ឬក្រុង-ស្រុក-ខណ្ឌ ហើយជាកម្មវត្ថុនៃពន្ធលើដីធ្លីមិនបានប្រើប្រាស់ ត្រូវបានអនុញ្ញាតឱ្យបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ចាប់ពីឆ្នាំទទួលសិទ្ធិកាន់កាប់ចុងក្រោយ ដោយផ្តល់ការអនុគ្រោះឱ្យដកចេញនូវមូលដ្ឋានគិតពន្ធ ១០០ ០០០ ០០០ (មួយរយលាន) រៀល និងផ្តល់ការលើកលែងប្រាក់ទោសទណ្ឌផ្សេងៗពាក់ព័ន្ធនឹងពន្ធនេះ។ ការអនុញ្ញាតឱ្យដកចេញនូវមូលដ្ឋានគិតពន្ធ និងប្រាក់ទោសទណ្ឌផ្សេងៗនេះ មានសុពលភាពអនុវត្តត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។

ផ្នែកទី៣

# ភារកិច្ច និងនីតិវិធីនៃការប្រកាសបង់ពន្ធ

## ៣.១. ភារកិច្ចនៃការដាក់លិខិតប្រកាស និងការបង់ប្រាក់ពន្ធ

ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ត្រូវបង់ដោយកម្មសិទ្ធិករ។ កម្មសិទ្ធិករនៃដីជាប់ពន្ធនិងអ្នកជួលដីពីរដ្ឋ ត្រូវគណនាប្រាក់ពន្ធទៅតាមទម្រង់ប្រកាសសារពើពន្ធដែលរដ្ឋបាលសារពើពន្ធបានផ្តល់ឱ្យ ហើយត្រូវស្នើសុំបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែកញ្ញា នៃឆ្នាំប្រមូលពន្ធនីមួយៗ នៅអគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារខេត្តដែលអចលនទ្រព្យនោះស្ថិតនៅ។ សម្រាប់ដីជាប់ពន្ធនីមួយៗ ត្រូវធ្វើប្រកាសសារពើពន្ធមួយដាច់ដោយឡែក។ ម្យ៉ាងវិញទៀត ការបង់ពន្ធនេះ មិនមែនជាលក្ខខណ្ឌបញ្ជាក់កម្មសិទ្ធិស្របច្បាប់របស់ម្ចាស់អចលនទ្រព្យនោះទេ។

## ៣.២. នីតិវិធីនៃដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធ

កម្មសិទ្ធិករនៃដីជាប់ពន្ធនិងអ្នកជួលដីពីរដ្ឋ អាចដាក់លិខិតប្រកាសបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ នៅអគ្គនាយកដ្ឋានពន្ធដារ ចំពោះដីដែលស្ថិតនៅរាជធានីភ្នំពេញនិងនៅខេត្ត ឬនៅសាខាពន្ធដារខេត្តដែលដីនោះស្ថិតនៅ និងបង់ប្រាក់ពន្ធនៅសាខាពន្ធដារខេត្ត ឬបង់ប្រាក់ពន្ធនៅសាខាធនាគារអេស៊ីលីដា ភីអិលស៊ី ឬធនាគារកាណាឌីយ៉ា ក.អ ឬធនាគារវឌ្ឍនៈ ឬធនាគារកម្ពុជាសាធារណៈ ឬធនាគារស្ថាបនា ភីអិលស៊ី ឬធនាគារជេត្រាស់ រ៉ូយ៉ាល់ ម.ក ឬធនាគារប្រៃសណីយ៍កម្ពុជា ក.អ ឬធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA) ឬធនាគារដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**កម្មសិទ្ធិករ**



❶ កម្មសិទ្ធិករនៃដីជាប់ពន្ធ ឬអ្នកជួលដីពីរដ្ឋ រៀបចំឯកសារស្នើសុំចុះបញ្ជី និងប្រកាសបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ មកអគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារខេត្តដែលដីនោះស្ថិតនៅ។

**អគ្គនាយកដ្ឋានពន្ធដារ / សាខាពន្ធដារខេត្ត**

❷ រដ្ឋបាលសារពើពន្ធទទួលឯកសារស្នើសុំប្រកាសបង់ពន្ធពីកម្មសិទ្ធិករ ដើម្បីពិនិត្យ វាយតម្លៃប្រាក់ពន្ធ និងដាក់ជូនថ្នាក់ដឹកនាំពិនិត្យសម្រេច។

**សាខាធនាគារដែលបានចុះអនុស្សរណៈ**




❸ បន្ទាប់ពីថ្នាក់ដឹកនាំឯកភាពលើការវាយតម្លៃប្រាក់ពន្ធ រដ្ឋបាលសារពើពន្ធនឹងបោះពុម្ព **“លិខិតប្រកាសបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់”** និង **“សេចក្តីជូនដំណឹងស្តីពីការបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់”** ចេញពីប្រព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធដារដើម្បីចុះហត្ថលេខា និងបង់ប្រាក់ពន្ធនៅធនាគារដែលបានចុះអនុស្សរណៈជាមួយអគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារខេត្ត។

**អគ្គនាយកដ្ឋានពន្ធដារ / សាខាពន្ធដារខេត្ត**



❹ កម្មសិទ្ធិករត្រូវយក “**បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ** (Single Invoice)” ចំនួន០២ សន្លឹកដែលធនាគារបានបោះពុម្ពមកប្រគល់ជូនរដ្ឋបាលសារពើពន្ធ ដើម្បីប្រថាប់ត្រាបញ្ចប់នីតិវិធី។ រដ្ឋបាលសារពើពន្ធនឹងផ្តល់នូវសំណុំឯកសារ (លិខិតប្រកាសបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធ) ដែលបានប្រថាប់ត្រារួចជូនកម្មសិទ្ធិករវិញ។

## ៣.៣. ទំនាក់ទំនងរវាងពន្ធលើអចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់

ដីជាកម្មវត្ថុត្រូវជាប់ពន្ធលើអចលនទ្រព្យដែលបានបង់ពន្ធរួចហើយ មិនត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ទៀតទេ សម្រាប់ឆ្នាំដែលត្រូវជាប់ពន្ធលើអចលនទ្រព្យ។ សម្រាប់ដីធ្លីមិនបានប្រើប្រាស់ និងមិនទាន់បានបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ក្នុងឆ្នាំដែលពុំជាប់ពន្ធលើអចលនទ្រព្យ ដីនោះនៅតែជាបំណុលពន្ធលើដីធ្លីមិនបានប្រើប្រាស់នៃឆ្នាំជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់។

> មាត្រា ១២ នៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ បានកែប្រែមាត្រា ២៩ នៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលមានខ្លឹមសារ "...មាត្រា ២៩._ថ្មី ពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវបង់ដោយកម្មសិទ្ធិករ ចំពោះដីដែលពុំមែនជាកម្មវត្ថុនៃពន្ធលើអចលនទ្រព្យ។"។

## ៣.៤. ឯកសារតម្រូវសម្រាប់ការបង់ពន្ធ

កម្មសិទ្ធិករនៃដីជាប់ពន្ធឬអ្នកជួលដីពីរដ្ឋដែលស្នើសុំបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ត្រូវធ្វើការចុះបញ្ជី ឬធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យ ដោយភ្ជាប់មកជាមួយនូវសំណុំឯកសារដូចខាងក្រោម÷

- ប័ណ្ណសម្គាល់សិទ្ធិ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់អចលនវត្ថុ ឬឯកសារពាក់ព័ន្ធនឹងការកាន់កាប់អចលនទ្រព្យដែលបញ្ជាក់ដោយអាជ្ញាធរឃុំ/ សង្កាត់ឡើងទៅ (ច្បាប់ចម្លង)
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្របញ្ជាក់កំណើត ឬលិខិតឆ្លងដែន ឬសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ របស់កម្មសិទ្ធិករ (ច្បាប់ថតចម្លង)
- រូបថតរបស់អចលនទ្រព្យ
- និយាមកាអចលនទ្រព្យ (រយៈទទឹង និងរយៈបណ្តោយ)
- បំពេញ "ពាក្យស្នើសុំចុះបញ្ជី ឬធ្វើបច្ចុប្បន្នភាពអចលនទ្រព្យសម្រាប់ការបង់ពន្ធលើអចលនទ្រព្យ FORM PT 01"។ ពាក្យស្នើសុំនេះ អាចស្វែងរកបាននៅរដ្ឋបាលសារពើពន្ធ ឬតាមរយៈតំណភ្ជាប់គេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ https://www.tax.gov.kh/km/document-form។

ក្នុងករណីអចលនទ្រព្យដែលស្នើសុំបង់ពន្ធធ្លាប់បានចុះបញ្ជី និងបានធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យ ក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់អគ្គនាយកដ្ឋានពន្ធដាររួចហើយ នោះកម្មសិទ្ធិករនៃដីជាប់ពន្ធឬអ្នកជួលដីពីរដ្ឋគ្រាន់តែភ្ជាប់មកនូវប័ណ្ណសម្គាល់ការបង់ពន្ធអចលនទ្រព្យ ឬបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់ពន្ធដែលបានបង់ឆ្នាំចាស់ មករដ្ឋបាលសារពើពន្ធធ្វើការវាយតម្លៃ និងបោះពុម្ពលិខិតប្រកាសបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ចេញពីប្រព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីបង់បន្ត។

**គំរូប័ណ្ណសម្គាល់ការបង់ពន្ធលើអចលនទ្រព្យ**




**គំរូបង្កាន់ដៃបញ្ជាក់ការបង់ប្រាក់**



# គំរូពាក្យស្នើសុំចុះបញ្ជី ឬធ្វើបច្ចុប្បន្នភាពអចលនទ្រព្យ
# សម្រាប់ការបង់ពន្ធលើអចលនទ្រព្យ FORM PT 01


ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

ទម្រង់ FORM PT 01

ពាក្យស្នើសុំចុះបញ្ជី ឬធ្វើបច្ចុប្បន្នភាពអចលនទ្រព្យសម្រាប់ការបង់ពន្ធលើអចលនទ្រព្យ
APPLICATION FORM FOR PROPERTY REGISTRATION OR PROPERTY TAX OR UPDATE

I. ព័ត៌មានម្ចាស់អចលនទ្រព្យ / PROPERTY OWNERS INFORMATION

ម្ចាស់កម្មសិទ្ធិទី១ / Property Owner No.1

ម្ចាស់កម្មសិទ្ធិទី២ / Property Owner No.2

នីតិបុគ្គល / Legal person


II. ព័ត៌មានអចលនទ្រព្យ / PROPERTY INFORMATION

១. ព័ត៌មានអចលនទ្រព្យ / PROPERTY INFORMATION

២. អាសយដ្ឋានអចលនទ្រព្យ / PROPERTY ADDRESS

៣. ទំហំអចលនទ្រព្យ / PROPERTY SIZE

សេចក្ដីប្រកាស / DECLARATION

I declare that information provided in this application including all attachments is true and correct.

ឯកសារភ្ជាប់ / ATTACHMENT CHECK-LIST

Note: All copied documents attached must be certified by tax official in charge or other ministries / institutions.

សម្រាប់មន្ត្រីពន្ធដារ / Tax official use only

# គំរូនិយាមការអចលនទ្រព្យ






# គំរូលិខិតប្រកាសបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់និងតារាងគណនាប្រាក់ពន្ធ



ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATIONAL RELIGION KING

លិខិតប្រកាស
បង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ឆ្នាំ ២០២០



ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តារាងគណនាប្រាក់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ត្រូវបង់ សម្រាប់ឆ្នាំ ២០២០

ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ

លិខិត ឬប័ណ្ណសម្គាល់អចលនទ្រព្យដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចលេខ ចុះថ្ងៃទី

ថ្ងៃខែឆ្នាំគណនាប្រាក់ពន្ធ៖ 05/10/2020 02:56:41 PM

| ឆ្នាំ | ផ្ទៃដីសរុប | ផ្ទៃដីលើកលែង | ផ្ទៃដីជាប់ពន្ធ | តម្លៃ/ម² | តម្លៃជាប់ពន្ធ | អត្រា | ប្រាក់ពន្ធត្រូវបង់ | ប្រាក់ទោសទណ្ឌ | | | | | សរុបប្រាក់ពន្ធត្រូវបង់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | ប្រាក់បន្ថែម ១០% | ចំនួនខែ | អត្រា(%) | ការប្រាក់ | សរុប | |
| 2020 | 593 | 0 | 593 | 15,000 | 8,895,000 | 2% | 177,900 | 17,790 | 1 | 1.5 | 2,669 | 20,459 | 198,359 |
| សរុប | 593.00 | 0.00 | 593.00 | 60,000,000 | 8,895,000 | | 177,900 | 17,790 | 1 | | 2,669 | 20,459 | 198,359 |

| | | |
|---|---|---|
| 2020 | : | 177,900 |
| ប្រាក់ពន្ធ | : | 177,900 |
| ប្រាក់ពិន័យ | : | 20,459 |
| សរុបរួម | : | 198,359 |

# គំរូសេចក្តីជូនដំណឹងស្តីពីការបង់ប្រាក់ពន្ធលើដីធ្លីមិនបានប្រើប្រាស់



ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
នាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

PIN008-21010600001

ថ្ងៃអង្គារ ១៣ កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១

សេចក្តីជូនដំណឹង
ស្តីពីការបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ២០០៩-២០១០

លោក-លោកស្រី÷ **អ្នកជាប់ពន្ធ A2** (TAXPAYER A2)
លេខទូរសព្ទ÷ **012000000**
អាសយដ្ឋាន÷ NA ផ្លូវ១១ ភូមិកប់គង សង្កាត់ទោមពោទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមជម្រាបជូន លោក-លោកស្រី ជាម្ចាស់កម្មសិទ្ធិអចលនទ្រព្យ ដែលមានអត្តសញ្ញាណកម្មអចលនទ្រព្យលេខ PIN008-21010600001 និងលិខិត ឬប័ណ្ណសម្គាល់អចលនទ្រព្យដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចលេខ **12090807-0298** ចុះថ្ងៃទី **23/01/2009** ដែលមានអាសយដ្ឋានលេខ #0298 ផ្លូវ គ្មាន ភូមិតៀនឃ្លាំង សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ អញ្ជើញទៅបង់ប្រាក់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ នៅតាមសាខាធនាគារណាមួយដែលនៅជិតលោក-លោកស្រី ដូចជា ធនាគារ អេស៊ីលីដា ភីអិលស៊ី ឬធនាគារ កាណាឌីយ៉ា ក.អ ឬធនាគារ វឌ្ឍនៈ ឬធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី ឬធនាគារ ស្ថាបនា ភីអិលស៊ី ឬធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក ឬធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ឬធនាគារ វឌ្ឍនៈ អាស៊ីចំកាត់ ដែលមានចំនួនទឹកប្រាក់ដូចខាងក្រោម÷

| ល.រ | ធនាគារ | គណនីពន្ធ | គណនីពិន័យពន្ធ | ប្រាក់ពន្ធ | ពន្ធបន្ថែមនិងការប្រាក់ | សរុបទឹកប្រាក់ត្រូវបង់ |
|---|---|---|---|---|---|---|
| ១ | ធនាគារ អេស៊ីលីដា ភីអិលស៊ី | 00010164849313 | 00010163564016 | 4,068,000 ៛ | 9,559,800 ៛ | 13,627,800 ៛ |
| ២ | ធនាគារ កាណាឌីយ៉ា ក.អ | 0010002196781 | 0010002196722 | | | |
| ៣ | ធនាគារ វឌ្ឍនៈ | 05001770002011 | 05001770002022 | | | |
| ៤ | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី | 0100122000112 | 0100122000129 | | | |
| ៥ | ធនាគារ ស្ថាបនា ភីអិលស៊ី | 09908107644300101 | 09908107644300201 | | | |
| ៦ | ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក | 3776229 | 3776241 | | | |
| ៧ | ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ | 910000000171 | 910000000187 | | | |
| ៨ | ធនាគារ វឌ្ឍនៈ អាស៊ីចំកាត់ | 001754377 | 001771425 | | | |

អាស្រ័យហេតុនេះ សូមលោក-លោកស្រី អញ្ជើញទៅបង់ប្រាក់ពន្ធ ឬ/និងពន្ធបន្ថែមនិងការប្រាក់តាមចំនួនទឹកប្រាក់ដូចបានជម្រាបជូនខាងលើនៅធនាគារណាមួយក៏បានតាមការជ្រើសរើសរបស់លោក-លោកស្រី ឱ្យបានឆាប់រហ័សយ៉ាងយឺតបំផុតត្រឹមកាលបរិច្ឆេទផុតកំណត់ថ្ងៃទី**៣០** ខែ**កញ្ញា** ឆ្នាំ**២០២១**។ ការយឺតយ៉ាវក្នុងការបង់ពន្ធនេះនឹងត្រូវរងនូវការបង់ពន្ធបន្ថែមនិងការប្រាក់តាមច្បាប់ជាធរមាន។ ក្នុងករណីមានការតវ៉ាលើការកំណត់ពន្ធខាងលើនេះ សូមសរសេរជាលាយលក្ខណ៍អក្សរមកកាន់អគ្គនាយកដ្ឋានពន្ធដារ ដែលមានអាសយដ្ឋានដូចខាងក្រោម។ សូមអរគុណ!

**ប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ**

៚ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកនាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ នៃអគ្គនាយកដ្ឋានពន្ធដារ
- អាសយដ្ឋាន អគារអគ្គនាយកដ្ឋានពន្ធដារ ឡូតិ៍លេខ ៩២២-៩២៤ កែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងវិថីលេខ (២៨៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
- ទូរស័ព្ទលេខ 023 884 818 សារអេឡិចត្រូនិក dpt@tax.gov.kh ឬ ផ្នែកបម្រើសេវាអតិថិជនលេខ 1277 ឬសេវា GDT Live Chat ដោយឥតគិតថ្លៃ

ផ្នែកទី៤

# ទោសទណ្ឌ និងសិទ្ធិក្នុងការតវ៉ា

## ៤.១. ការយឺតយ៉ាវក្នុងការបំពេញកាតព្វកិច្ច

ក្នុងករណីខកខានមិនបានដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ឱ្យបានទាន់ពេលវេលាកំណត់សម្រាប់ឆ្នាំជាប់ពន្ធនីមួយៗទេ កម្មសិទ្ធិករនៃដីជាប់ពន្ធឬអ្នកជួលដីពីរដ្ឋ នឹងត្រូវទទួលរងទោសទណ្ឌ ដូចមានចែងក្នុងមាត្រា ១៣១ និងមាត្រា ១៣២ នៃច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧ ជាធរមាន÷

**១. ការធ្វេសប្រហែស÷** ប្រាក់ពន្ធបន្ថែមត្រូវស្មើនឹង ១០ភាគរយ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ ២ភាគរយ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធខ្វះមិនទាន់បានបង់។

**២. ការធ្វេសប្រហែសធ្ងន់ធ្ងរ÷** ការមិនបង់ប្រាក់ពន្ធក្នុងរយៈពេល ១៥ថ្ងៃ ក្រោយទទួលបានលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ ប្រាក់ពន្ធបន្ថែមត្រូវស្មើនឹង ២៥ភាគរយ នៃប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ ២ភាគរយ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធខ្វះមិនទាន់បានបង់។

**៣. ការកំណត់ពន្ធជាឯកតោភាគី÷** ការមិនមកប្រកាសបង់ពន្ធ ប្រាក់ពន្ធបន្ថែមស្មើ ៤០ភាគរយ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់ ២ភាគរយ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធខ្វះមិនទាន់បានបង់។

អត្រាការប្រាក់ខាងលើត្រូវបានកែប្រែពី ២ភាគរយ ទៅ ១,៥ភាគរយ យោងតាមប្រការ ១៧ នៃប្រកាសលេខ ២៧០ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីសវនកម្មពន្ធដារ និងមាត្រា៩ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០២០ ដែលបានចែងថា "...ពាក្យ "ការប្រាក់ ២ភាគរយ" ដែលមានចែងក្នុងមាត្រា១៣១ និងមាត្រា ១៣២ ត្រូវបានប្តូរទៅជា "ការប្រាក់ ១,៥ភាគរយ"។"។

## ៤.២. សិទ្ធិក្នុងការតវ៉ា

កម្មសិទ្ធិករនៃដីជាប់ពន្ធឬអ្នកជួលដីពីរដ្ឋ ដែលមិនពេញចិត្តនឹងការកំណត់ពន្ធ សេចក្តីសម្រេច ឬវិធានការផ្សេងៗរបស់រដ្ឋបាលសារពើពន្ធ មានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ា ទៅអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារក្នុងរយៈពេល **៣០ថ្ងៃ នៃថ្ងៃធ្វើការ** គិតចាប់ពីកាលបរិច្ឆេទ នៃការទទួលសេចក្តីជូនដំណឹងស្តីពីការបង់ប្រាក់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ឬសេចក្តីសម្រេច ឬវិធានការផ្សេងៗរបស់រដ្ឋបាលសារពើពន្ធ។

## ៤.៣. ពាក្យបណ្តឹងតវ៉ា

ពាក្យបណ្តឹងតវ៉ា ត្រូវចុះហត្ថលេខាដោយអ្នកតវ៉ាផ្ទាល់ ឬតំណាងស្របច្បាប់។ អ្នកតវ៉ាអាចចាត់តំណាងស្របច្បាប់ដែលមានសិទ្ធិសម្រេច ដោយភ្ជាប់ជាមួយលិខិតផ្ទេរសិទ្ធិដែលមានចុះហត្ថលេខារបស់សាមីអ្នកតវ៉ា ដើម្បីចូលរួមជំនួសក្នុងនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ា។

ពាក្យបណ្តឹងតវ៉ា ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយត្រូវមានខ្លឹមសារ និងព័ត៌មាន ដូចខាងក្រោម÷

- កាលបរិច្ឆេទនៃបណ្តឹងតវ៉ា
- អត្តសញ្ញាណរបស់អ្នកជាប់ពន្ធ (អត្តសញ្ញាណប័ណ្ណ ឬសំបុត្រកំណើត ឬលិខិតឆ្លងដែន)
- លេខអត្តសញ្ញាណកម្មសារពើពន្ធ (ករណីអ្នកតវ៉ាជានីតិបុគ្គល)

-អាសយដ្ឋាន លេខទូរស័ព្ទ និង/ ឬសារអេឡិចត្រូនិក របស់អ្នកតវ៉ា ឬអ្នកតំណាងស្របច្បាប់
-ឯកសារយោងដែលជាកម្មវត្ថុនៃបណ្តឹងតវ៉ា
-អង្គហេតុ ឬវិធានការដាក់ចេញដោយអគ្គនាយកដ្ឋានពន្ធដារ ឬអង្គភាពកំណត់ពន្ធ ដែលជាកម្មវត្ថុនៃបណ្តឹងតវ៉ា
-សំអាងហេតុ និងមូលដ្ឋានគតិយុត្ត នៃបណ្តឹងតវ៉ា ដែលសាមីអ្នកតវ៉ាលើកជាសំអាង ក្នុងការតវ៉ា
-ព័ត៌មានចាំបាច់ផ្សេងទៀតពាក់ព័ន្ធបណ្តឹងតវ៉ា

**គំរូពាក្យតវ៉ាសម្រាប់អ្នកជាប់ពន្ធ**
**រូបវន្តបុគ្គល**


ឧបសម្ព័ន្ធ នៃប្រកាសលេខ១៤៦៦សហវ.ប្រក
ចុះថ្ងៃទី ០៦ ខែកក្កដាឆ្នាំ២០១៩

**គំរូទី១. ពាក្យបណ្តឹងតវ៉ា របស់អ្នកជាប់ពន្ធជារូបវន្តបុគ្គល**

**ពាក្យបណ្តឹងតវ៉ារបស់អ្នកជាប់ពន្ធ**

ឈ្មោះ÷
អត្តសញ្ញាណ÷ (លេខអត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន)
អាសយដ្ឋាន÷
លេខទូរស័ព្ទ÷
សារអេឡិចត្រូនិច÷

....., ថ្ងៃទី..... ខែ..... ឆ្នាំ.....

**សូមគោរពជូន**
**ឯកឧត្តម (លោកជំទាវ) អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**កម្មវត្ថុ** ÷ ..... ។
**យោង** ÷ - (សេចក្តីសម្រេច ឬវិធានការណ៍ និងកាលបរិច្ឆេទ ដែលជាកម្មវត្ថុនៃបណ្តឹង)
- (លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ បើសិនជាមាន)
- (ឯកសារ ឬភស្តុតាង)។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូនឯកឧត្តម (លោកជំទាវ) អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ មេត្តាជ្រាបថា ផ្អែកតាម (សេចក្តីសម្រេច ឬវិធានការណ៍ ដោយមានបញ្ជាក់កាលបរិច្ឆេទ ដែលអ្នកតវ៉ាមិនពេញចិត្ត) ខ្ញុំបាទ/នាងខ្ញុំ យល់ឃើញ ដូចខាងក្រោម÷
ក. អង្គហេតុ
.....
ខ. មូលដ្ឋាន និងសំអាងហេតុ
.....
គ. សន្និដ្ឋាន
.....
អាស្រ័យហេតុនេះ ខ្ញុំសូមឯកឧត្តម អគ្គនាយកមេត្តាពិនិត្យនិងដោះស្រាយលើពាក្យបណ្តឹងរបស់ខ្ញុំបាទ/នាងខ្ញុំ ខាងលើ ដោយក្តីអនុគ្រោះ។
សូមឯកឧត្តម (លោកជំទាវ) អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារទទួលនូវការគោរព អំពីខ្ញុំបាទ/នាងខ្ញុំ

ឈ្មោះអ្នកតវ៉ា ឬតំណាងស្របច្បាប់
ហត្ថលេខា ឬ ស្នាមមេដៃ

**គំរូពាក្យតវ៉ាសម្រាប់អ្នកជាប់ពន្ធ**
**នីតិបុគ្គល**


**គំរូទី២. ពាក្យបណ្តឹងតវ៉ា របស់អ្នកជាប់ពន្ធជានីតិបុគ្គល**

**ពាក្យបណ្តឹងតវ៉ារបស់អ្នកជាប់ពន្ធ**

នាមករណ៍ក្រុមហ៊ុន÷
អត្តសញ្ញាណ÷ (VAT IN/PIN/...)
អាសយដ្ឋានទីស្នាក់ការ÷
លេខទូរស័ព្ទ÷
សារអេឡិចត្រូនិច÷ ....., ថ្ងៃទី..... ខែ..... ឆ្នាំ.....

**សូមគោរពជូន**
**ឯកឧត្តម (លោកជំទាវ) អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**កម្មវត្ថុ** ÷ ..... ។
**យោង** ÷ - (សេចក្តីសម្រេច ឬវិធានការណ៍ និងកាលបរិច្ឆេទ ដែលជាកម្មវត្ថុនៃបណ្តឹង)
- (លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ បើសិនជាមាន)
- (ឯកសារ ឬភស្តុតាង)។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូនឯកឧត្តម (លោកជំទាវ) អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ មេត្តាជ្រាបថា ផ្អែកតាម (សេចក្តីសម្រេច ឬវិធានការណ៍ ដោយមានបញ្ជាក់កាលបរិច្ឆេទ ដែលអ្នកតវ៉ាមិនពេញចិត្ត) ខ្ញុំបាទ/នាងខ្ញុំ យល់ឃើញ ដូចខាងក្រោម÷
ក. អង្គហេតុ
.....
ខ. មូលដ្ឋាន និងសំអាងហេតុ
.....
គ. សន្និដ្ឋាន
.....
អាស្រ័យហេតុនេះ ខ្ញុំសូមឯកឧត្តម អគ្គនាយកមេត្តាពិនិត្យនិងដោះស្រាយលើពាក្យបណ្តឹងរបស់ខ្ញុំបាទ/នាងខ្ញុំ ខាងលើ ដោយក្តីអនុគ្រោះ។
សូមឯកឧត្តម (លោកជំទាវ) អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារទទួលនូវការគោរព អំពីខ្ញុំបាទ/នាងខ្ញុំ

តំណាងស្របច្បាប់របស់ក្រុមហ៊ុន
ហត្ថលេខា
(ត្រារបស់ក្រុមហ៊ុន)

ផ្នែកទី៥

# សេវាអ្នកជាប់ពន្ធ និងព័ត៌មានបន្ថែម

## ៥.១. ចម្ងល់ផ្សេងៗ និងការពិគ្រោះយោបល់

ករណីកម្មសិទ្ធិករមានចម្ងល់ផ្សេងៗពាក់ព័ន្ធនឹងការស្នើសុំបង់ប្រាក់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ សូមទំនាក់ទំនងតាមរយៈ Call Center របស់អគ្គនាយកដ្ឋានពន្ធដារលេខ **១២៧៧** ដោយឥតគិតថ្លៃ ឬផ្ញើសារមកកាន់ GDT Live Chat ឬសារអេឡិចត្រូនិក dpt@tax.gov.kh។ កម្មសិទ្ធិករក៏អាចមកទំនាក់ទំនងដោយផ្ទាល់នៅអគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារខេត្ត ដែលមានអាសយដ្ឋានដូចខាងក្រោម÷

**អគ្គនាយកដ្ឋានពន្ធដារ**
អាសយដ្ឋានលេខ ៥២២-៥២៤ កែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងមហាវិថីម៉ៅសេទុង (២៤៥)
សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ÷ (៨៥៥) ២៣ ៨៨៦ ៧០៨
សារអេឡិចត្រូនិក÷ info@tax.gov.kh

**នាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ**
អាសយដ្ឋានលេខ ៥២២-៥២៤ កែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងមហាវិថីម៉ៅសេទុង (២៤៥)
សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ÷ (៨៥៥) ២៣ ៨៨៤ ៨១៨
សារអេឡិចត្រូនិក ÷ dpt@tax.gov.kh

**សាខាពន្ធដារខេត្តកណ្ដាល**
ផ្ទះលេខ១០៣ ផ្លូវលេខ១០៨
សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល
ទូរស័ព្ទ÷ (៨៥៥) ២៣ ៩៨៣ ៤២៣
សារអេឡិចត្រូនិក÷ kandal@tax.gov.kh

**សាខាពន្ធដារខេត្តកំពង់ចាម**
ផ្ទះលេខ៥ ផ្លូវខេមរភូមិន្ទ
សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម
ទូរស័ព្ទ÷ (៨៥៥) ៤២ ៣៩១ ៥៣៩
សារអេឡិចត្រូនិក÷ kampongcham@tax.gov.kh

**សាខាពន្ធដារខេត្តបាត់ដំបង**
ផ្ទះលេខ២ ផ្លូវជាតិលេខ៥
សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង
ទូរស័ព្ទ÷ (៨៥៥) ៥៣ ៩៥៣ ៩៦៣
សារអេឡិចត្រូនិក÷ battambang@tax.gov.kh

**សាខាពន្ធដារខេត្តតាកែវ**
ផ្លូវភូមិ១ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ
ទូរស័ព្ទ÷ (៨៥៥) ៣២ ៩៣១ ២៣៩
សារអេឡិចត្រូនិក÷ takeo@tax.gov.kh

**សាខាពន្ធដារខេត្តស្វាយរៀង**
ផ្លូវភូមិរោងបន្លែ សង្កាត់ស្វាយរៀង
ក្រុងស្វាយរៀង ខេត្តស្វាយរៀង
ទូរស័ព្ទ÷ (៨៥៥) ៤៤ ៩៤៥ ៧៤១
សារអេឡិចត្រូនិក÷ svayrieng@tax.gov.kh

**សាខាពន្ធដារខេត្តពោធិ៍សាត់**
ផ្លូវជាតិលេខ៥ សង្កាត់ព្រៃញី
ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់
ទូរស័ព្ទ÷ (៨៥៥) ៥២ ៧៤០ ០៧៤
សារអេឡិចត្រូនិក÷ pursat@tax.gov.kh

**សាខាពន្ធដារខេត្តកំពង់ឆ្នាំង**
ភូមិឃ្លាំងប្រាក់ ឃុំប្អេរ
ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង
ទូរស័ព្ទ÷ (៨៥៥) ២៦ ៧៧០ ០០៤
សារអេឡិចត្រូនិក÷ kampongchhnang@tax.gov.kh

**សាខាពន្ធដារខេត្តកំពង់ស្ពឺ**
ផ្លូវជាតិលេខ៤ ភូមិត្រពាំងលើក សង្កាត់រកាធំ
ក្រុងច្បារមន ខេត្តកំពង់ស្ពឺ
ទូរស័ព្ទ÷ (៨៥៥) ២៥ ៩៨៧ ៣៨៩
សារអេឡិចត្រូនិក÷ kampongspeu@tax.gov.kh

## សាខាពន្ធដារខេត្តព្រៃវែង
អគារកែងផ្លូវលេខ៥ និងផ្លូវលេខ៣ ភូមិ២
សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង
ទូរស័ព្ទ៖ (៨៥៥) ៤៣ ៦៩ ០០ ១៦៨
សារអេឡិចត្រូនិក៖ preyveng@tax.gov.kh

## សាខាពន្ធដារខេត្តសៀមរាប
ផ្លូវជាតិលេខ៦
សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប
ទូរស័ព្ទ៖ (៨៥៥) ៦៣ ៩៦៤ ៦៦៥
សារអេឡិចត្រូនិក៖ siamreap@tax.gov.kh

## សាខាពន្ធដារខេត្តកំពង់ធំ
ផ្លូវជាតិលេខ៦ ភូមិត្រឡាំងលិច សង្កាត់ដំរីជាន់ខ្លា
ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
ទូរស័ព្ទ៖ (៨៥៥) ១២ ៩៦០ ១៤២ / ១១ ៧៧៥ ២៩៦
សារអេឡិចត្រូនិក៖ kampong_thom@tax.gov.kh

## សាខាពន្ធដារខេត្តកោះកុង
ភូមិ២ សង្កាត់ស្មាច់មានជ័យ
ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
ទូរស័ព្ទ៖ (៨៥៥) ៣៥ ៩៣៦ ០៤១
សារអេឡិចត្រូនិក៖ kohkong@tax.gov.kh

## សាខាពន្ធដារខេត្តព្រះវិហារ
ភូមិកណ្តាល សង្កាត់កំពង់ប្រណាក
ក្រុងព្រះវិហារ ខេត្តព្រះវិហារ
ទូរស័ព្ទ៖ (៨៥៥) ៩៧ ៧០៧ ២១១៧
សារអេឡិចត្រូនិក៖ preahvihear@tax.gov.kh

## សាខាពន្ធដារខេត្តក្រចេះ
ផ្ទះលេខ៧៣ សង្កាត់ក្រចេះ
ក្រុងក្រចេះ ខេត្តក្រចេះ
ទូរស័ព្ទ៖ (៨៥៥) ៧២ ៩៧១ ៤៤៤
សារអេឡិចត្រូនិក៖ kratie@tax.gov.kh

## សាខាពន្ធដារខេត្តរតនៈគិរី
ផ្លូវភូមិអូរកន្សែង សង្កាត់បឹងកន្សែង
ក្រុងបានលុង ខេត្តរតនៈគិរី
ទូរស័ព្ទ៖ (៨៥៥) ៩៧ ៦៤១ ១៥៥៥
សារអេឡិចត្រូនិក៖ ratanakiri@tax.gov.kh

## សាខាពន្ធដារខេត្តកំពត
ភូមិ១ឧសភា សង្កាត់កំពង់កណ្តាល
ក្រុងកំពត ខេត្តកំពត
ទូរស័ព្ទ៖ (៨៥៥) ៣៣ ៩៣២ ៧១១
សារអេឡិចត្រូនិក៖ kampot@tax.gov.kh

## សាខាពន្ធដារខេត្តព្រះសីហនុ
ផ្លូវ២៨មិថុនា សង្កាត់លេខ៣
ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
ទូរស័ព្ទ៖ (៨៥៥) ៣៤ ៩៣៤ ៤៥៤
សារអេឡិចត្រូនិ៖ preahsihanouk@tax.gov.kh

## សាខាពន្ធដារខេត្តស្ទឹងត្រែង
ផ្លូវភូមិស្ពានថ្ម សង្កាត់ស្ទឹងត្រែង
ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង
ទូរស័ព្ទ៖ (៨៥៥) ៧៤ ៦៣០ ៣៣៦
សារអេឡិចត្រូនិក៖ stoengtreng@tax.gov.kh

## សាខាពន្ធដារខេត្តកែប
ផ្លូវ៣៣A ភូមិកែប សង្កាត់កែប
ក្រុងកែប ខេត្តកែប
ទូរស័ព្ទ៖ (៨៥៥) ១២ ៨២៨ ៧៣៩ / ១២ ៧៧៩ ៤៥៦
សារអេឡិចត្រូនិក៖ kep@tax.gov.kh

## សាខាពន្ធដារខេត្តប៉ៃលិន
ភូមិបឱនាវ សង្កាត់ប៉ៃលិន
ក្រុងប៉ៃលិន ខេត្តប៉ៃលិន
ទូរស័ព្ទ៖ (៨៥៥) ១៦ ៨៨២ ៩០៥
សារអេឡិចត្រូនិក៖ pailin@tax.gov.kh

## សាខាពន្ធដារខេត្តឧត្តរមានជ័យ
ភូមិឈូក សង្កាត់សំរោង
ក្រុងសំរោង ខេត្តឧត្តរមានជ័យ
ទូរស័ព្ទ៖ (៨៥៥) ៤២ ៤៧៤ ៧០៤៧
សារអេឡិចត្រូនិក៖ odormeanchey@tax.gov.kh

## សាខាពន្ធដារខេត្តត្បូងឃ្មុំ
ផ្លូវជាតិលេខ៧ ភូមិពោធិរោងលិច ឃុំកោងកាង
ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ
ទូរស័ព្ទ៖ (៨៥៥) ៤២ ៤៧៤ ៧០៤៧
សារអេឡិចត្រូនិក៖ tboungkhmum@tax.gov.kh

## សាខាពន្ធដារខេត្តមណ្ឌលគិរី

ភូមិកណ្តាល សង្កាត់ស្ពានមានជ័យ
ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី
ទូរស័ព្ទ៖ (៨៥៥) ៩៧ ៦២៨ ២៩២៩
សារអេឡិចត្រូនិក៖ mondulkiri@tax.gov.kh

## សាខាពន្ធដារខេត្តបន្ទាយមានជ័យ

ផ្លូវជាតិលេខ៥ ភូមិក្បាលស្ពាន សង្កាត់ព្រះពន្លា
ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ
ទូរស័ព្ទ៖ (៨៥៥) ៥៤ ៩៥៨ ៩៩២
សារអេឡិចត្រូនិក៖ banteaymeanchey@tax.gov.kh

ឧបសម្ព័ន្ធ

# ច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធលើដីធ្លីមិនបានប្រើប្រាស់

## ច្បាប់

- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៤
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៧ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦
- ច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម ០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១ នស ៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤

## អនុក្រឹត្យ

- អនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មធិការដោះស្រាយវិវាទសារពើពន្ធ
- អនុក្រឹត្យលេខ ៥៨ អ.ន.ក្រ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃដីធ្លីមិនបានប្រើប្រាស់

## ប្រកាស

- ប្រកាសលេខ ១២៤ សហវ.ប្រក ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់
- ប្រកាសលេខ ១៤៧០ សហវ.ប្រក ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ាពន្ធដារ នៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ប្រកាសលេខ ៤៥២ សហវ.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៧ ស្តីពីការកែប្រែប្រកាសស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- ប្រកាសលេខ ៧៤៤ ប្រក.សហវ.ពដ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៩៦ ស្តីពីការកំណត់មេគុណសម្រាប់អនុវត្តក្នុងការងារប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- ប្រកាសលេខ ២២៤ ប្រក.សហវ.ពដ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់

## សេចក្តីសម្រេច

- សេចក្តីសម្រេចលេខ ០៣៧ សហវ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលសមាសភាពអនុគណៈកម្មការវាយតម្លៃដីសម្រាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ រាជធានីភ្នំពេញ
- សេចក្តីសម្រេចលេខ ០០៧ សសរ.សហវ.ពដ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការកំណត់តម្លៃគិតពន្ធលើដីធ្លីមិនបានប្រើប្រាស់

- សេចក្តីសម្រេចលេខ ០០៤ សសរ.សហវ.ពដ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៩៨ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់

## សារាចរណែនាំ

- លិខិតលេខ ២៨៥១៧ អពដ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានពន្ធដារ
- លិខិតលេខ ៣៦៧ សជណ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- សារាចរណែនាំលេខ ០១៧ សរន.សហវ.ពដ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តពន្ធលើដីធ្លីមិនបានប្រើប្រាស់

អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥)
សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទលេខ៖ ០២៣ ៨៨៦ ៧០៨
សារអេឡិចត្រូនិក៖ gdt@tax.gov.kh
គេហទំព័រ៖ www.tax.gov.kh
ផ្នែកបម្រើសេវាអតិថិជនលេខ ១២៧៧ ឬ សេវា GDT Live Chat ដោយឥតគិតថ្លៃ

© រក្សាសិទ្ធិ
អគ្គនាយកដ្ឋានពន្ធដារ